# ប្រវត្តិពុទ្ធសាសនា

*រៀបរៀងដោយ*

*ព្រះញាណវីរិយៈ វ៉ាន-សាឃុំ*

*ដកស្រង់ចេញពីទស្សនាវដ្ដីកម្ពុជសុរិយា*

*ឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា*

*ព.ស.២៥០០-២៥០១ គ.ស.១៩៥៨*

***

# វប្បធម៌ពុទ្ធសាសនា

រៀបរៀងដោយ

ព្រះញាណវីរិយៈ វ៉ាន-សាឌុំ

ដកស្រង់ចេញពីទស្សនាវដ្ដីកម្ពុជសុរិយា

ឆ្នាំទី៣០ លេខ៦-៧ ខែមិថុនា-កក្កដា

ព.ស.២៥០០-២៥០១ គ.ស.១៩៥៨

***

អ្វីជាវប្បធម៌? អ្វីជាពុទ្ធសាសនា?

–សភាពសព្វយ៉ាងដែលតាំងភូមិប្រទេស ជាអំពើផ្សេងៗ មានការគោះពានក្ខរាស់សាបព្រោះបណ្ដុះដាំផ្សាំបំប៉ោជាដើមឬក្នុងកាយប្រទេស ដោយការសិក្សាអប់រំបណ្ដុះនិស្ស័យសន្ដាន នេះជាវប្បធម៌។

–ធម៌វិន័យដែលព្រះពុទ្ធទ្រង់សម្ដែង ទ្រង់បញ្ញត្តទុកប្រោសសត្វលោក ហៅថា ពុទ្ធសាសនា។ ពុទ្ធសាសនាជាវប្បធម៌កើតអំពីព្រះពុទ្ធ។ ព្រះពុទ្ធ កាលដែលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយទ្រង់ទេសនាប្រោសសត្វទូទៅ ហៅថា ទ្រង់បានសាបព្រោះបណ្ដុះដាំផ្សាំវប្បធម៌ព្រះពុទ្ធសាសនាក្នុងពិភពលោក។

## វប្បធម៌ឥណ្ឌាសម័យបុរាណនិងសម័យពុទ្ធកាល

ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះសម្ភពនិងទ្រង់ត្រាស់ដឹងនៅប្រទេសឥណ្ឌាភាគ

ខាងជើង ដែលក្នុងសម័យនោះគេទុកជាមជ្ឈិមប្រទេស។ សម័យនោះឥណ្ឌាភាគខាងជើងមានអារ្យធម៌ខ្ពស់ថ្កើងជាងភាគខាងត្បូង ដោយមានវប្បធម៌ខាងបច្ចេកទេសនិងខាងរដ្ឋប្បសាសនោបាយ ព្រមទាំងខន្តីនិងវិរិយៈសំខាន់ជាង។ ឥណ្ឌាភាគខាងជើងមានឥទ្ធិពលខ្លាំងក្លា អាចទម្លាក់ឋានៈឥណ្ឌាភាគខាងត្បូងឲ្យថោកទាបដូចឋាននរក សូម្បីតែក្នុងឥណ្ឌាភាគខាងជើងជាមួយគ្នាក៏បែងឋានៈប្រជាជនជា៤ត្រកូល គឺត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលវៃស្យៈ (ឈ្មួញ) ត្រកូលសូទ្រៈ (អ្នកងារ)។ បណ្ដាត្រកូលទាំង៤នេះ ត្រកូលក្សត្រនិងត្រកូលព្រាហ្មណ៍ ជាត្រកូលឧត្តមដោយមានវប្បធម៌ជាន់ខ្ពស់ ត្រកូលវៃស្យៈជាត្រកូលបន្ទាប់បន្សំ ដោយមានវប្បធម៌ថ្នាក់កណ្ដាល ត្រកូលសូទ្រៈ ជាត្រកូលទាបជាងគេបង្អស់ដោយមានវប្បធម៌ថោកទាបបំផុត កាលបើមានវប្បធម៌ផ្សេងគ្នាតាមឋានៈត្រកូលដូច្នេះ អារ្យធម៌សេចក្ដីចម្រើនរុងរឿងដោយអាកប្បកិរិយាទាំងឡាយ មានសម្លៀកបំពាក់និងសីលធម៌ ចរិយាជាដើមក៏ផ្សេងគ្នាទៅតាមនោះ។ ដល់ព្រះពុទ្ធជាម្ចាស់បានត្រាស់មក ទ្រង់ផ្សាយអនុត្តរធម៌ ទ្រង់ទម្លាយឋានៈចំពោះជនដែលមកពីត្រកូលទាំង៤នោះ ទោះបីត្រកូលណាក៏ដោយឲ្យតែចូលបួសក្នុងធម្មវិន័យរបស់ព្រះអង្គ ទ្រង់ទុកដាក់ឋានៈជាស្មើគ្នាទាំងអស់ ឲ្យគោរពគ្នានឹងគ្នាតែតាមវស្សាចាស់ខ្ចីនិងការចេះដឹងតិចច្រើនប៉ុណ្ណោះ ហើយនឹងទ្រង់អប់រំនិស្ស័យពុទ្ធបរិស័ទ ដោយនាយកធម៌នានា មានទាន សីល ភាវនាឬសីល សមាធិ បញ្ញាជាដើម រហូតដល់មគ្គផលនិព្វានជាទីបំផុត។ ដូច្នេះឈ្មោះថា ព្រះពុទ្ធជាម្ចាស់ទ្រង់បានសាបព្រោះបណ្ដុះដាំផ្សាំពូជ

វប្បធម៌ពុទ្ធសាសនា ទុកក្នុងប្រទេសឥណ្ឌា ជាមជ្ឈិមប្រទេស ដែលជាជាតិភូមិរបស់ព្រះអង្គក្នុងសម័យពុទ្ធកាល។ លុះព្រះអង្គបរិនិព្វានទៅ ទើបវប្បធម៌នោះសាយភាយចេញទៅកាន់ប្រទេសនានាជាបច្ចន្តប្រទេស ដរាបដល់ទូទៅទាំងពិភពលោកដូចឃើញប្រាកដក្នុងសម័យបច្ចុប្បន្ននេះ។

## វប្បធម៌ពុទ្ធសាសនាផ្សាយមកកាន់សុវណ្ណភូមិ

បច្ចន្តប្រទេសទាំងពួងក្នុងឧបទ្វីបសុវណ្ណភូមិ បានទទួលយកវប្បធម៌ពុទ្ធសាសនាមកសាបព្រោះបណ្ដុះដាំនៅសម័យក្រោយពុទ្ធកាល គឺក្នុងសតវត្សរ៍ទី៣នៃពុទ្ធសករាជ នារជ្ជកាលអសោកមហារាជ ដោយព្រះមោគ្គល្លិបុត្ត-តិស្សត្ថេរជាសង្ឃប្រមុខ បានចាត់ព្រះថេរៈ២រូប គឺព្រះសោណត្ថេរ១ ព្រះឧត្តរ-ត្ថេរ១ ឲ្យជាសមណទូតនាំវប្បធម៌ពុទ្ធសាសនាមកផ្សាយដល់សុវណ្ណភូមិ ដែលតាមប្រភពខ្លះថាតាំងនៅក្នុងអាណាចក្រភូមា ដែលមានអរហន្តសីមានិងសិលាចារឹកជាព័ស្តុតាង នៅរហូតដល់សម័យបច្ចុប្បន្ននេះ។

ឯប្រទេសកម្ពុជាយើង បើតាមសិលាចារឹកក្នុងចេតិយដ្ឋាននានានៅសតវត្សរ៍ទី៨នៃព.ស. សម័យនគរភ្នំ (ហ្វូណន់) ប្រាកដថាមានពុទ្ធសាសនាមកចាក់ឫសលូតលាស់ពាសពេញអាណាខេត្តទៅហើយ។ កាលបើដូច្នេះ អាចសន្និដ្ឋានថា ប្រទេសកម្ពុជាបានទទួលវប្បធម៌ពុទ្ធសាសនាតាំងពីមុនសម័យនោះទៅទៀត គឺថាប្រហែលតាំងពីសតវត្សរ៍ទី៣ឬទី៤នៃព.ស. ដំណាលឬបន្ទាប់គ្នានឹងប្រទេសភូមានោះដែរ ព្រោះទំរាំនឹងកើតបានជាសិលាចារឹកបែបនេះ ក៏អាស្រ័យមានជនានុជនជឿគោរពកាន់មកមុនយូរក្រែលដែរហើយ ទាំង

សម័យនោះនៅឧបទ្វីបសុវណ្ណភូមិយើង មានប្រជាជាតិតែ៣ផង គឺភាគខាងលិចប្រជាជាតិមន, ភាគខាងកើតប្រជាជាតិចាម, ភាគកណ្តាលប្រជាជាតិខ្មែរ។ ដូច្នេះឃើញថាប្រជាជាតិទាំង៣អាចផ្សាយឬអាចចម្លងវប្បធម៌ទៅវិញទៅមកបានដោយងាយ, ហើយបើនឹកដល់រឿងមួយទៀតថាជាតិខ្មែរនិងជាតិមនមានអម្បូរភាសាជាមួយគ្នា ដែលហៅថាភាសាមនខ្មែរប្រាកដមកឥឡូវនេះ ក៏រឹតតែឃើញថាសមណាស់ទៅទៀត។ រួមហេតុការណ៍ទាំងអស់ទៅអាចសន្និដ្ឋានថា វប្បធម៌ពុទ្ធសាសនាខាងថេរវាទ ដែលជាគូនឹងអាចរិយវាទ បានមកចាក់ឫសដុសដាលក្នុងប្រទេសយើង តាំងពីសម័យនគរភ្នំ។ ជាតិខ្មែរដែលធ្លាប់តែកាន់សាសនាព្រាហ្មណ៍មកពីមុនៗ ក៏បែរត្រឡប់មកកាន់ពុទ្ធសាសនាទាំងព្រះមហាក្សត្រ ទាំងអាណាប្រជារាស្ត្រ កាន់តែច្រើនឡើងៗ។ លុះចូលមកដល់សម័យចេនឡា គឺពីសតវត្សរ៍ទី១១ទៅទី១៤នៃព.ស. ក្នុងរវាងនេះវប្បធម៌ពុទ្ធសាសនាខាងអាចរិយវាទ ក៏បានផ្សាយចូលមកដល់ទៀត បានចាក់ឫសលូតលាស់ឡើងជាគូនឹងសាសនាព្រាហ្មណ៍ ដោយមានឥទ្ធិពលផ្សាយចូលកាន់ព្រះរាជសម្នាក់ក្នុងរជ្ជកាលខ្លះៗផង ដរាបមកដល់សម័យអង្គរ គឺពីសតវត្សរ៍ទី១៤ទៅទី២០នៃព.ស. ក្នុងរវាងនេះនារជ្ជកាលខ្លះក៏រឹតតែមានឥទ្ធិពលយ៉ាងអស្ចារ្យ មានព្រះមហាក្សត្រគោរពរាប់អានថ្វាយព្រះអង្គជាពុទ្ធសាសនិក ដូចព្រះបាទជយវរ្ម័នទី៧ ដែលមានព្រះកិត្តិនាមល្បីល្បាញ មានព្រះរាជអាណាខេត្តដ៏ធំទូលាយក្នុងសតវត្សរ៍ទី១៨នៃព.ស.។ ក្នុងរជ្ជកាលព្រះអង្គ ទ្រង់បានសាងចេតិយដ្ឋានសំខាន់ៗ មានប្រាសាទតាព្រហ្ម ព្រះខ័ននិងបាយ័នជាដើម ដែល

ទុកជាវប្បធម៌ខាងការរចនានៃព្រះពុទ្ធសាសនាលទ្ធិអាចរិយវាទ ទាំងបានសាង មន្ទីរពេទ្យ ស្ពាន ថ្នល់ សាលាសម្នាក់ជាសពាសក្នុងព្រះរាជអាណាចក្រ។ តាមសិលាចារឹកក្នុងបុរាណស្ថានទាំងឡាយ បំភ្លឺឲ្យឃើញថា ព្រះអង្គជាបណ្ឌិតឯកមួយ ទាំងខាងសាសនោបាយ ទាំងខាងនយោបាយ។ ទាំងព្រះនាងជយរាជទេវី អគ្គមហេសីព្រះអង្គក៏ជាសាស្ត្រាចារ្យខាងព្រះពុទ្ធសាសនា។

## មូលហេតុព្រះត្រៃបិដកស្លឹករឹត

វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ តាំងពីព្រះពុទ្ធជាម្ចាស់គង់ព្រះធរមាននៅជរាបមក លោកអ្នកបម្រើព្រះពុទ្ធសាសនាទាំងឡាយគ្រាន់តែរៀនសូត្រឲ្យចេះចាំ ហើយបង្ហាត់បង្រៀននិងប្រជុំសង្គាយនាជោគក្រងធម្មវិន័យជាបិដក៣ (ព្រះត្រៃបិដក) និងផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវរួចចាំទុកតៗគ្នាមកដោយការស្វាធ្យាយន៍ លើកពុទ្ធវចនៈឡើងកាន់ចិត្តទាំងអស់ ឥតមានចារឹកដាក់ស្លឹករឹតឬដាក់ផ្ទាំងសិលា ដូចដែលយើងធ្លាប់បានឃើញនៅប្រទេសយើងនិងប្រទេសភូមាជាដើមទេ។ សូម្បីវប្បធម៌ពុទ្ធសាសនាហូរចូលមកចាក់ឫសក្នុងប្រទេសខ្មែរ លូតលាស់បិតនៅជរាបទល់រជ្ជកាលព្រះបាទជយវរ្ម័ននទី៧ ហើយអត្ថបទព្រះត្រៃបិដកនេះ ក៏មិនប្រាកដថាមាននៅឡើយ។ ឃើញមានតែអត្ថបទបន្តិចបន្តួចដែលចារឹកនៅផ្ទាំងថ្ម ដូចក្នុងសម័យអសោកមហារាជដែរ។ លុះមកដល់រជ្ជកាលព្រះបាទជយវរ្ម័ននទី៧ ទើបមានរឿងតំណាលថា ព្រះអង្គបានបញ្ជូនព្រះរាជបុត្រឲ្យទៅបួសរៀននៅកោះសិរីលង្កា នៅសតវត្សរ៍ទី១៨ នៃព.ស. ហើយវិលមកប្រទេសវិញក្នុងសតវត្សរ៍ដដែល។ ក្នុងព្រះដំណើរ

បំពេញបេសកកម្មនៃព្រះថេរៈជាព្រះរាជបុត្រនេះ គង់មានកុលបុត្រខ្មែរច្រើនរូបតាមហែជាសហការី ហើយគង់មាននាំព្រះត្រៃបិដកស្លឹករឹតនិងឧបករណ៍ឯទៀតច្រើនមកកាន់ប្រទេសខ្លួននៅវេលាត្រឡប់វិញ។

## វប្បធម៌ពុទ្ធសាសនាផ្នែកអក្សរសាស្ត្រ

វប្បធម៌ខាងអក្សរសាស្ត្រពុទ្ធសាសនា ទុកជាគ្រឿងរចនាពិសេសមួយតាំងឡើងដោយសារព្រះពុទ្ធនិងព្រះអនុពុទ្ធ លោកអ្នកបម្រើព្រះពុទ្ធសាសនា។ ព្រះពុទ្ធជាម្ចាស់យើង ដោយព្រះអង្គទ្រង់បានស្តេចចេញទៅសាងអភិនិស្រ្កមប្រព្រឹត្តទុក្ករកិរិយាអស់៦ព្រះវស្សា ហើយបានត្រាស់ដឹងជាព្រះពុទ្ធនៅដែនមគធៈជងនិងដោយព្រះអង្គត្រូវសម្តែងធម៌ប្រោសវេនេយ្យសត្វ ក្នុងដែននេះជាមុនផង ទើបទ្រង់យកភាសាអ្នកដែននេះដែលហៅថា មគធភាសា មកប្រើប្រកាសធម្មវិន័យដែលទ្រង់បានត្រាស់ដឹង គឺសម្តែងធម៌ បញ្ញត្តិវិន័យ ដោយភាសានេះទាំងអស់។

ពីដើមមក មគធភាសា សម្រាប់ប្រើការតាមធម្មតាស្រុក មិនទាន់រាប់ថាជាតន្តិភាសា ដូចភាសាសំស្រ្កឹតទេ លុះព្រះពុទ្ធទ្រង់យកមកប្រើក្នុងការផ្សាយព្រះពុទ្ធសាសនា ក៏បានទទួលការរចនាក្លាយទៅជាតន្តិភាសា (ភាសាមានរបៀប) ប្រកបដោយលិង្គ វចនៈ វិភត្តិ កាល បទ បច្ច័យជាដើមយ៉ាងបរិបូណ៌ ហើយផ្ទុកដោយច្បាប់ធម្មវិន័យ មានអត្ថរសដ៏ជ្រាលជ្រៅ។ មគធភាសា មានពាក្យហៅម្យ៉ាងទៀតថា បាលីភាសា ជាភាសាសម្រាប់ប្រកាសធម្មវិន័យពុទ្ធសាសនានេះ ដល់មកក្នុងបឋមសង្គីតិកាល ព្រះសង្គីតិការកៈទាំងឡាយ បាន

ចាត់ការរួបរួមទៅជាព្រះត្រៃបិដក៣ ដោយយកបាលីដទៃៗ មានបាលីនិង និទានជាដើមមកបញ្ចូលផ្សំផង។ បាលីដើមដែលបានឡើងកាន់សង្គាយនាទាំង នោះ ចាត់ជាបករណ៍មួយឈ្មោះថា មូលប្បករណ៍ (គម្ពីរដើម) ឬហៅថា បាលី ដដែលក៏បាន។ បករណ៍ជាអត្ថវណ្ណនា (សម្រាប់ពិពណ៌នាសេចក្តី) នៃបាលី នេះហៅថា អដ្ឋកថា។ បករណ៍ជាអត្ថវណ្ណនានៃបករណ៍ទាំងពីរ គឺបាលីនិង អដ្ឋកថា ហៅថា ដីកា។ បករណ៍ក្រៅពីនេះ មានវិសុទ្ធិមគ្គនិងមង្គលត្ថទីបនី ជាដើមហៅថា តព្វិនិមុត្តឬបករណវិសេស។

ឯព្រះបករណ៍ទាំងឡាយមានអដ្ឋកថាជាដើម កើតឡើងជាលំដាប់តាំង ពីអរហន្តសម័យ ហើយច្រើនតែជាបាលីភាសា។ ទោះមានបករណ៍ខ្លះតាំង នៅជាភាសាដទៃ ក៏ពួកពុទ្ធសាវកទាំងឡាយនាំគ្នាប្រែមកជាបាលីភាសាវិញ។ ដូចរឿងព្រះពុទ្ធឃោសាចារ្យអ្នកស្រុកមគធៈ បាននិមន្តទៅលង្កាទ្វីបប្រែអដ្ឋ-កថាចេញពីសីហឡភាសាមកជាបាលីភាសានៅពុទ្ធសតវត្សទី១០ គឺធ្វើភាសា ដែលកត់អដ្ឋកថានោះឲ្យទៅជាបាលីភាសា ស្របទៅតាមភាសាដែលកត់ មូលប្បករណ៍ ដើម្បីឲ្យផ្សាយទៅកាន់ប្រទេសនានាបានដោយស្រួល។

មួយទៀត បាលីភាសានេះនឹងហៅថា ពុទ្ធភាសាក៏បាន ព្រោះជាភាសា បច្ចេកទេសមួយក្នុងចំណោមមគធភាសា ហើយកើតឡើងដោយការរចនា របស់ព្រះពុទ្ធ។ កាលខ្ញុំ (អ្នកសរសេររឿងនេះ) ទៅបំពេញបេសកកម្មក្នុងឆដ្ឋ សង្គាយនានៅប្រទេសភូមា ខ្ញុំបានឮព្រះថេរវាចាព្រះសង្ឃិតិការកៈខ្លះថា យើង បានស្គាល់គ្នាជរាបដល់ទុកចិត្តស្និទ្ធស្នាល ដោយសារយើងចេះពុទ្ធភាសាដូច

អ្នកស្គាល់តម្លៃពេទ្យដោយសារចេះភាសាពេទ្យ។

សព្វថ្ងៃអ្នកស្រុកភូមាក្តី ឥណ្ឌាក្តី កាលប្រាថ្នាឲ្យយល់អត្ថរសដ៏ជ្រាលជ្រៅនៃបាលីពុទ្ធភាសា គេតែងទៅនៅអប់រំ នៅប្រទេសសិរីលង្កា ដូចព្រះរាជបុត្រស្តេចខ្មែរពីសម័យបុរាណដែរ គេជឿថា ប្រទេសនេះ បានសិក្សាហាត់រៀនក្នុងអត្ថបទបាលីពុទ្ធភាសាតមកអំពីអ្នកប្រាជ្ញទាំងឡាយ មានព្រះមហិន្ទ-ត្ថេរអង្គអរហន្តជាដើមដែលជាអ្នកស្រុកមគធៈ (ជម្ពូទ្វីប) ហើយបានសង្គាយនាធម្មវិន័យរក្សាទុកដរាបមក។ សូម្បីប្រទេសភូមា ដែលបានចារឹកព្រះត្រៃបិដកមួយចប់ ចុះក្នុងសិលាកែវចំនួន៧២៩ផ្ទាំង នៅដើមពុទ្ធសតវត្សរ៍២៥នេះ ក៏ដោយសារបានចម្លងគម្ពីរស្លឹករឹតពីប្រទេសសិរីលង្កាដែរ។

## ព្រឹត្តិការណ៍វប្បធម៌ពុទ្ធសាសនានៅកម្ពុជរដ្ឋ

ខ្ញុំបានពណ៌នាមកហើយថា វប្បធម៌ពុទ្ធសាសនាបានមកចាក់ឫសចាក់គល់ក្នុងប្រទេសតាំងពីសម័យនគរភ្នំ (ហ្វូណន) ឬមុននេះទៅទៀត តែវប្បធម៌នេះតែងមានវប្បធម៌សាសនាព្រាហ្មណ៍ ដែលមានមកជាយូរដែរហើយនោះជាគូប្រឆាំងឬជាឧបសគ្គ ព្រោះក្នុងរជ្ជកាលតៗមក មានព្រះមហាក្សត្រច្រើនព្រះអង្គឬមន្ត្រីធំៗ ជាព្រាហ្មណិក (កាន់សាសនាព្រាហ្មណ៍) ហើយព្រះអង្គខ្លះទៀត បានតាំងព្រះអង្គជាគូប្រឆាំងឬជាសត្រូវនឹងវប្បធម៌ខាងពុទ្ធសាសនាទាល់តែមានប្រកពខ្លះថា ក្នុងកាលខ្លះព្រះពុទ្ធសាសនាសាបសូន្យពីប្រទេសខ្មែរទៅហើយក៏មាន ដូចក្នុងរជ្ជកាលតមកពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ សម័យអង្គរ មានមហាក្សត្រអង្គខ្លះជាព្រាហ្មណិក លើកតម្កើងវប្បធម៌ព្រាហ្មណ៍

បំបាត់វប្បធម៌ពុទ្ធសាសនា ដូចមានវប្បធម៌ខាងការរចនារបស់ព្រាហ្មណ៍ នៅប្រាសាទបាយ័នឋិតនៅមកដល់សព្វថ្ងៃជាឧទាហរណ៍ស្រាប់។

ដំណើរខាងលើនេះ ធ្វើឲ្យឃើញរឹតតែជ្រះថ្លាចំពោះគុណានុភាពព្រះពុទ្ធសាសនាថែមឡើងទៀត ព្រោះព្រះពុទ្ធសាសនាជាសាសនាស្លូតសុភាព ទោះក្នុងរជ្ជកាលណាក៏ដោយ តាំងពីសម័យនគរភ្នំដល់ផុតសម័យអង្គរ ព្រះមហាក្សត្រជាពុទ្ធសាសនិកទាំងឡាយ មិនដែលតាំងព្រះអង្គជាគូសត្រូវនឹងសាសនាដទៃដល់ម្ដងទេ បើខ្លាំងណាស់គ្រាន់តែមិនគោរពរាប់អានថ្វាយព្រះអង្គជាសាសនូបត្ថម្ភក៏ប៉ុណ្ណោះ ឧទាហរណ៍ដូចប្រាសាទនគរវត្ត ដែលធ្លាប់ធ្លាក់នៅក្នុងកណ្ដាប់ព្រហស្តព្រះមហាក្សត្រជាពុទ្ធសាសនិក ឃើញគង់រូបនៅតាមដើមគ្រប់គ្រឿងរចនាអ្វីៗទាំងអស់។ ដោយវប្បធម៌ពុទ្ធសាសនាស្លូតសុភាពបែបនេះហើយ មានការផ្សព្វផ្សាយទៅកាន់វេនេយ្យសត្វ បើកសិទ្ធិឲ្យប្រើវិចារណញ្ញាណដេញដោលនឹងឥតមានការបង្ខិតបង្ខំ ក៏ទៅជាមានអានុភាពអាចចាក់ឫសដុះដាលក្នុងសន្ដានប្រជាជនដាស់ពាសពេញទាំងដែន ទោះបីមានព្រះមហាក្សត្រឬមន្ត្រីធំៗជាគូសត្រូវយ៉ាងណាក៏ដោយ បើខ្លាំងណាស់គ្រាន់តែប្រជាជនពុំអាចចេញមុខប្រកាសខ្លួនថាជាពុទ្ធសាសនិកប៉ុណ្ណោះ ឧទាហរណ៍ដូចរដ្ឋបុរសសំខាន់ៗទាំងឡាយរបស់ប្រទេសឥណ្ឌា មានលោកគន្ធី លោកវាជេន្ទ្រប្រាសាទនិងលោកនេរុជាដើម បើទុកជាលោកទាំងនេះ ពុំបានប្រកាសខ្លួនជាពុទ្ធសាសនិក ក៏អាចឃើញថា វប្បធម៌ពុទ្ធសាសនាចាក់ឫសជ្រួតជ្រាបយ៉ាងជ្រាលជ្រៅក្នុងសន្ដានរបស់លោកទាំងនេះស្រេចទៅហើយ ព្រោះក្នុង

សម័យមុនព្រះពុទ្ធត្រាស់ គ្មាននរណាអាចពោលធម៌អាចិប្រកបដោយហេតុផល ហើយមានសន្តានស្រឡាញ់ភាតរភាពនិងសមភាព តាមរបបលទ្ធិប្រជាធិបតេយ្យដូច្នេះទេ។ នឹងថា ព្រះពុទ្ធជាមូលនិទ្ទាការទៅខាងលទ្ធិនេះក៏ដោយព្រោះព្រះអង្គប្រកបដោយព្រះមហាករុណា មានព្រះអធ្យាស្រ័យដ៏ធំទូលាយគ្មានទីបំផុត។ ព្រះពុទ្ធសាសនាកើតក្រោយសាសនាព្រាហ្មណ៍ តែមានវប្បធម៌ខាងទស្សនវិជ្ជាប្រកបដោយអត្ថរសដ៏ជ្រាលជ្រៅក្រៃលែង ផុតវិស័យលទ្ធិព្រាហ្មណ៍។ សាសនាគ្រិស្តនិងសាសនាមោហាម៉ត់ ទោះបីមានដើមកំណើតនៅទ្វីបអាស៊ីដូចព្រះពុទ្ធសាសនាដែរ ហើយកើតក្រោយព្រះពុទ្ធសាសនាផងក៏មិនឃើញមានអត្ថរសណាពិសេសជាងព្រះពុទ្ធសាសនាឡើយ ឃើញគ្រាន់បើតែត្រង់បបួលនិងបង្ខំគេឲ្យជឿព្រះអាទិទេព ដូចពួកព្រាហ្មណ៍បបួលគេឲ្យជឿគោរពកោតខ្លាចព្រះព្រហ្ម ព្រះឥសូរនិងព្រះនារាយណ៍។ ហេតុនេះឃើញថា វប្បធម៌ពុទ្ធសាសនាជាកំពូលខាងទស្សនវិជ្ជានៅទ្វីបអាស៊ី។ ចំណែកទ្វីបដទៃដែលទើបតែចម្លងយកវប្បធម៌ទៅពីទ្វីបអាស៊ីក្រោយពុទ្ធកាល ដូចទ្វីបអាមេរិកបានទទួលវប្បធម៌ពីទ្វីបអឺរ៉ុបនោះ មិនបានចាត់ជាបញ្ហាត្រូវដោះស្រាយក្នុងទីនេះទេ។ រួមសេចក្តីទៅអាចឃើញថា ព្រះពុទ្ធជាកំពូលអ្នកប្រាជ្ញក្នុងការរាវរកហេតុផលទាំងខាងរូបសាស្ត្រទាំងចិត្តសាស្ត្រ។

## វប្បធម៌ពុទ្ធសាសនាសម័យក្រោយអង្គរ

ដោយវប្បធម៌ពុទ្ធសាសនាបានចាក់ឫសក្នុងសន្តានជនជាតិខ្មែរតាំងពីបុរាណកាលមក លុះដល់សម័យអង្គរ គឺរយៈវេលាពីពុទ្ធសតវត្សទី២០ដល់ទី

២៥នេះ ទោះមានហេតុការណ៍ចលាចលជាញឹកញាយ ដោយពួកជនបរទេសចូលលុកលុយស្រុក រឹបជាន់បំផ្លិចបំផ្លាញជីវិតនិងភោគសម្បត្តិជាដើមយ៉ាងណា ក៏ប្រជាជនខ្មែរនៅតែព្យាយាមឱបពទាំងត្រដាប់ត្រដួសនូវព្រះពុទ្ធសាសនាមិនបោះបង់សោះឡើយ គឺនៅតែនាំគ្នាចូលបួសជាភិក្ខុសាមណេរ ថ្វាយខ្លួនជាឧបាសក ឧបាសិកានិងសាងវត្តអារាមសម្រាប់ព្រះសង្ឃគ្រប់ឃុំខេត្តនៃព្រះរាជាណាចក្រ។ សូម្បីកន្លែងណាធ្លាប់ជាវត្តអារាមរបស់សាសនាព្រាហ្មណ៍ ក៏បែរទៅជារបស់ព្រះពុទ្ធសាសនាស្ទើរតែទាំងអស់។ ម្ល៉ោះហើយវប្បធម៌ព្រាហ្មណ៍ ដោយគ្មានអ្នកគោរពរាប់អានក៏សាបសូន្យអស់ទៅ នៅសល់តែគ្រឿងរចនានិងការទំនៀមទម្លាប់បន្តិចបន្តួចក្នុងពិធីខ្លះ មានព្រះរាជពិធីអភិសេកជាដើមប៉ុណ្ណោះ។ អាស្រ័យជនជាតិខ្មែរភាគច្រើនជាពុទ្ធសាសនិកនិងមានព្រះមហាក្សត្រជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទើបប្រទេសខ្មែរក៏ជាប្រទេសពុទ្ធសាសនិកពេញទី ហើយទទួលស្គាល់តាមរដ្ឋធម្មនុញ្ញនូវព្រះពុទ្ធសាសនាថាជាសាសនារបស់រដ្ឋថែមទៀត។

ក្នុងសម័យបច្ចុប្បន្ន នាពុទ្ធសតវត្សទី២៥នេះ ប្រទេសខ្មែរមានភព្វសំណាងលើសលប់ជាងសតវត្សរ៍មុនៗ ដែលមានមកបន្ទាប់ពីសម័យអង្គរ ព្រោះបានឯករាជ្យមានអធិបតេយ្យបរិបូណ៌ទាំងខាងក្នុងទាំងខាងក្រៅ ហើយមានទីបណ្ដុះវប្បធម៌ខាងពុទ្ធសាសនា គឺកើតមានសាលារៀនធម្មវិន័យ សាលាពុទ្ធិកបឋមសិក្សា សាលាពុទ្ធិកវិទ្យាល័យ សាលាពុទ្ធិកមហាវិទ្យាល័យ ពុទ្ធសាសនបណ្ឌិត្យ ក្រុមជំនុំព្រះត្រៃបិដក សមាគមមិត្តពុទ្ធិកវិទ្យាល័យនិងពុទ្ធិក

សមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ព្រមទាំងមានព្រះសង្ឃបានបំពេញគន្ថធុរៈ រៀនប្រឡងជាប់ថ្នាក់ជាអ្នកធម្មវិទូ ជាមហាបធានវិជ្ជានិងជាមហាឧត្តមវិជ្ជាច្រើនពាន់រូប ហើយបញ្ជូនព្រះមហាឧត្តមវិជ្ជាច្រើនរូបឲ្យទៅសិក្សាអប់រំបំពេញវិជ្ជាក្នុងប្រទេសផ្សេងៗ មានប្រទេសឥណ្ឌានិងភូមាជាដើម។

ដំណើរការខាងលើនេះ នាំឲ្យប្រទេសខ្មែរមានកម្លាំងល្មមពេញចិត្តធ្វើបុណ្យសម្ពោធលើកស្ទួយព្រះពុទ្ធសាសនា ដែលមានអាយុគម្រប់ប្រាំពាន់វស្សានេះផងនិងនាំឲ្យមានការសង្ឃឹមថា វប្បធម៌ពុទ្ធសាសនាទាំងខាងទ្រឹស្តីទាំងខាងប្រតិបត្តិ រឹងរឹតតែចាក់ឫសដុះលូតលាស់ចម្រើនធំទូលាយទូទាំងក្នុងពិភពលោកផង។

## វប្បធម៌ពុទ្ធសាសនាខាងទ្រឹស្តី

ជនជាតិខ្មែរ ធ្លាប់យល់ឃើញតាមព្រះពុទ្ធសាសនាថា ការថ្លៃថ្នូរថោកទាបបរិសុទ្ធិនិងមិនបរិសុទ្ធិ កើតមកអំពីខ្លួន មានខ្លួនជាទីសម្គាល់ មិនមែនកើតដោយស្នាដៃទេវតាណាមួយ។ សូម្បីព្រះពុទ្ធជាគ្រូដើម ក៏បានទទួលការថ្លៃថ្នូរបរិសុទ្ធិ ព្រោះអំពើដែលជាសំណាងរបស់ព្រះអង្គដែរ។ កាលទ្រង់បំពេញពុទ្ធកិច្ច ទ្រង់គ្រាន់តែប្រាប់ផ្លូវនៃសេចក្តីថ្លៃថ្នូរបរិសុទ្ធិ ទ្រង់មិនអាចប្រទានសេចក្តីថ្លៃថ្នូរបរិសុទ្ធិដល់គេដែលមិនធ្វើដំណើរតាមផ្លូវនោះផងបានទេ។ កាលមានវប្បធម៌ខាងទ្រឹស្តីដូច្នេះ ទោះជនជាតិខ្មែរធ្វើការអ្វីដែលទាក់ទិនដោយពិធីបន់ស្រន់ ក៏ធ្វើគ្រាន់តែជាទំនៀមទម្លាប់ជាប់តមកពីព្រាហ្មណសម័យប៉ុណ្ណោះ មិន

មែនជឿថា ទោះបីគ្មានអំពើសមហេតុផល ក៏អាចថ្លៃថ្នូរបរិសុទ្ធិបានដែរ។ ទាន សីលនិងភាវនា ចាត់ជាអំពើដែលសមហេតុផលនៃសេចក្ដីថ្លៃថ្នូរបរិសុទ្ធិ។ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ដែលបានទទួលសេចក្ដីថ្លៃថ្នូរបរិសុទ្ធិ ក៏ព្រះតែអំពើនេះទាំងអស់។ ពុទ្ធការកធម៌១០ប្រការមានទានជាដើម មាន ឧបេក្ខាជាអវសាន ដែលហៅថា ទសបារមី ក៏សង្គ្រោះចូលក្នុងអំពើនេះដែរ។

## វប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ

ដោយសារទ្រឹស្ដីមានដើមដូចបានពោលមកហើយនេះ ជនជាតិខ្មែរក៏មានសទ្ធាជ្រះថ្លាក្នុងទាន សីលនិងភាវនាផង។ ដោយសារសទ្ធាជ្រះថ្លានេះ ទើបខំបំពេញទាន សីលនិងភាវនា ធ្វើខ្លួនឲ្យទៅជាអ្នកសីលនិងអ្នកភាវនា។ ករណីយកិច្ចក្នុងជីវិតរបស់ជនជាតិខ្មែរ តែងមានអំពើ គឺទាន សីលនិងភាវនា នេះជាទីជ្រះថ្លានិងជាទីកក់ក្ដៅជរាបដល់អស់អាយុសង្ខារ ព្រោះឃើញថាមានតែអំពើនេះទេដែលអាចសាងខ្លួនឲ្យទៅជាមនុស្សល្អ ត្រូវតាមព្រះពុទ្ធសាសនា ហើយសមគួរដល់ខ្លួនដែលកើតហើយត្រូវចាស់ស្លាប់។

### អ្នកទាន

អ្នកទានជាតិខ្មែរ តែងធ្វើទានដោយអនុគ្រោះផង ដោយបូជាផង ជនខ្វះខាតគួរធ្វើទានដោយអនុគ្រោះ, ជនមិនខ្វះខាតទេតែមានគុណធម៌ល្អ គួរគេធ្វើទានដោយបូជា បើខ្វះខាតផង មានគុណធម៌ល្អផង គួរគេធ្វើទានដោយអនុគ្រោះផង ដោយបូជាផង។ ដូច្នេះដើម្បីឲ្យបានផលានិសង្សច្រើនសមគួរដល់ទានដែលមានគុណអាចកម្ចាត់មច្ឆរិយៈ ចិត្តចង្អៀតហើយធ្វើចិត្តឲ្យទូលាយ

ជនជាតិខ្មែរទើបនិយមធ្វើទានដល់ពួកបព្វជិតក្នុងពុទ្ធសាសនា ជាងពួកជនឯទៀត ដរាបដល់ភ្លេចគិតមាតាបិតាក៏មាន មកពីឃើញថាពួកនេះតែងមានការខ្វះខាតគួរអនុគ្រោះផង មានគុណគួរបូជាផង ការធ្វើទានដល់ពួកនេះ ជាមធ្យោបាយពង្រីកសេចក្ដីសុខចម្រើន ឲ្យរីកធំទូទៅដល់សព្វសត្វឥតរើសមុខ ព្រោះពួកនេះជាអ្នកបម្រើពុទ្ធសាសនា។ ដោយធ្លាប់មានប្រពៃណីធ្វើទានតាំងពីបុរាណកាល ទោះបីស្រុកទេសធ្លាក់ក្នុងវិបត្តិធំៗ ខ្សត់អ្នកប្រាជ្ញគម្ពីរក្បួនខ្នាត ដូចក្នុងសម័យខ្លះមានសម័យក្រុងលង្វែកជាដើម ជនជាតិខ្មែរក៏នៅតែរក្សាប្រពៃណីធ្វើទានដរាប។ បុណ្យឆ្លងវាលុកចេតិយ និមន្តព្រះសង្ឃស្រង់ទឹកចូលឆ្នាំ បុណ្យចូលវស្សា បុណ្យភ្ជុំបិណ្ឌ បុណ្យចេញវស្សា បុណ្យមាឃបូជានិងបុណ្យវិសាខបូជាជាដើម សុទ្ធតែមានការធ្វើសក្ការៈគោរពរាប់អានបូជាព្រះរតនត្រ័យ ដោយអាមិសបូជានិងបដិបត្តិបូជាជាប្រពៃណីទាំងអស់។ ហេតុនេះបានជាវប្បធម៌ព្រះពុទ្ធសាសនា មិនរលើងឫសសាបសូន្យទៅពីប្រទេសខ្មែរឡើយ ទោះប្រទេសនេះមានការភ័ន្តប្រែចលាចលឬមានជាតិសាសន៍ដទៃនាំសាសនាជាគូប្រឆាំងមកផ្សាយយ៉ាងណាក៏ដោយ។

## អ្នកសីល

អ្នកសីលជាតិខ្មែរ ដែលមានប្រាជ្ញាតែងរក្សាសីលមាននិច្ចសីលជាដើម ដើម្បីវៀរចាកការបៀតបៀនជនដទៃផង ដើម្បីផ្ដាច់កង្វល់អាក្រក់ដោយកាយវាចាជាហេតុក្ដៅក្រហាយចិត្តផង ដើម្បីរម្ងាប់ពៀរវេរានិងសាងសេចក្ដីកក់ក្ដៅទុកចិត្តគ្នាក្នុងលោកផង ព្រោះជនទ្រុស្តសីលគ្មានអភយទានទេ ប្រែសេចក្ដី

ថាជាអ្នកឲ្យតែសេចក្ដីភ័យបារម្ភ ឲ្យតែសេចក្ដីមិនទុកចិត្តដល់គ្នានឹងគ្នា។ អ្នកសីលមិនអាចដើរឧបាយបំបាត់ទ្រព្យសង្ឃ ទ្រព្យរាជការ ទ្រព្យឯកជនឬទទួលសំណូកយកទៅចិញ្ចឹមខ្លួន ចិញ្ចឹមគ្រួសារឬធ្វើបុណ្យទានអ្វីៗឡើយ។ ហេតុនេះសីលអាចជាទីកក់ក្ដៅទុកចិត្តនិងជាទីពឹងរបស់រដ្ឋទៀតផង។ រដ្ឋបើមានអ្នកសីលជាពលរដ្ឋច្រើននឹងពុំអាចធ្លាក់ខ្លួនទៅជាបាវព្រាវរដ្ឋណាដោយងាយៗទេ។ ដូច្នេះទើបរដ្ឋខ្លះខំអប់រំពលរដ្ឋឲ្យមានសីលធម៌តាំងពីក្មេងៗរហូតដល់ទៅបំបាត់មិនឲ្យបិទស្រាក្នុងស្រុកនិងមិនឲ្យស្រាអាគៀនចូលស្រុកទៀតផង ដូចគ្រួសារដែលមានសីលធម៌ល្អមិនចង់ឲ្យមានល្បែងស៊ីសងឡើងផ្ទះ ព្រោះខ្លាចមានការខូចអាក្រក់ដល់កូនចៅ។ អ្នកប្រាជ្ញទាំងឡាយតែងឃើញអំពើទ្រុស្តសីលឬល្បែងស៊ីសងថាជាភ័យរបស់លោកសន្និវាស ទើបមានហិរិឱត្តប្បៈខ្ពើមខ្លាចអំពើទាំងនេះ ដូចគេខ្ពើមខ្លាចពស់អាសិរពិសដែលពេនត្រាំក្នុងលាមក។ កាលបើលោកសន្និវាសមានសីលធម៌ល្អ លោកសន្និវាសនឹងមិនមានការបៀតបៀនគ្នា។ អាស្រ័យការមិនបៀតបៀនគ្នា សេចក្ដីសុខក៏មានឡើង សមនឹងពុទ្ធនិទានថាៈ អព្យាបជ្ឈំ សុខំ លោកេ ការមិនបៀតបៀនគ្នាជាសុខក្នុងលោក។ ជនជាតិខ្មែរធ្លាប់ជាអ្នកមានសីលធម៌បែបនេះមកតាំងពីបុរាណកាល តែមិនមានចំនួនច្រើនជាងមនុស្សទ្រុស្តសីលទេ។ តទៅគួរណាស់តែរដ្ឋរកមធ្យោបាយអប់រំពលរដ្ឋ ឲ្យទៅជាអ្នកសីលមានភាគច្រើនឡើង ដើម្បីជាទីពឹងនៃរដ្ឋ។

## អ្នកភាវនា

អ្នកភាវនាជាតិខ្មែរ តែងមានការចម្រើនភាវនានិងការនមស្ការ (ថ្វាយបង្គំព្រះ) ជាប្រពៃណីតាំងពីបុរាណកាល។ ក្រៅពីចម្រើនភាវនាក្នុងបូជនីយដ្ឋានមានព្រះបដិមាឃរៈ (ព្រះវិហារ) ជាដើម តែងភាវនានៅទីកុដិនិងនៅគេហស្ថានដែលហៅថា ធ្វើវត្តព្រឹកនិងវត្តល្ងាច។ នៅកុដិព្រះសង្ឃនិងផ្ទះឧបាសក តែងមានតុតាំងតម្កល់ព្រះពុទ្ធរូបព្រមទាំងគ្រឿងសក្ការបូជាដែលហៅថា គ្រែព្រះធម៌ ជាទីគោរពនមស្ការនិងជាទីចម្រើនភាវនា។ ឯការចម្រើនភាវនានោះ គេតែងមានការចម្រើនចតុរារក្ខកម្មដ្ឋានជាគោលគឺៈ

ក) ចម្រើនភាវនារឭកពុទ្ធគុណ ធម្មគុណនិងសង្ឃគុណ ដើម្បីបណ្ដុះចិត្តសទ្ធាជ្រះថ្លាក្នុងព្រះគុណទាំងនោះ មិនឲ្យចិត្តរួញរាឬសោយចេញពីកុសលធម៌។

ខ) ចម្រើនព្រហ្មវិហារ គឺភាវនាផ្សាយមេត្តាដល់សត្វទួទៅ ដោយតាំងចិត្តឲ្យបានកប់ប្រទះតែនូវសេចក្ដីសុខចម្រើនគ្រប់គ្នា, ផ្សាយករុណាដោយប្រាថ្នាឲ្យបានរួចរដោះចាកទុកគ្រប់ប្រាណ ផ្សាយមុទិតាដោយប្រាថ្នាមិនឲ្យប្រាសព្រាត់ចាកសេចក្ដីសុខដែលបានហើយទាំងអស់គ្នា, ផ្សាយឧបេក្ខាដោយគិតថា សត្វទាំងអស់គ្នាតែងមានកម្មជារបស់ខ្លួន គឺថាបើខ្លួនធ្វើល្អនឹងទទួលផលល្អ ធ្វើអាក្រក់នឹងទទួលផលអាក្រក់ ដើម្បីកម្ចាត់បង់ចិត្តព្យាបាទ ចិត្តវិប្បដិសារីនិងចិត្តឫស្យាឈ្នានីសគ្នាជាដើម។

គ) ចម្រើនអសុភភាវនា ពិចារណារាងកាយ ដែលជាទីប្រជុំធាតុ៤ឲ្យ

ឃើញថាពោរពេញដោយអាការៈស្មោកគ្រោកមិនស្អាត មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម។

ឃ) ចម្រើនមរណសតិភាវនា នឹកពិចារណាសេចក្តីស្លាប់ដែលត្រូវមានដល់ខ្លួនដោយទៀងទាត់ តែមិនប្រាកដថាមានមកដល់ថ្ងៃណា ព្រោះជីវិតមិនទៀង ដើម្បីបណ្តុះចិត្តសង្វេគហើយប្រញាប់ចាប់ធ្វើការដែលមានខ្លឹមសារ ឲ្យសមគួរដល់ខ្លួនដែលមានសេចក្តីស្លាប់ចាំស្កាត់ពីខាងមុខ។

ការចម្រើនភាវនាដែលរៀបរាប់មកនេះ ជាពិធីសាងសេចក្តីស្ងប់សុខក្សេមក្សាន្តក្នុងចិត្ត ហើយអាចញ៉ាំងចិត្តជាទានជាសីល ឲ្យរឹតតែមានដំហររឹងប៉ឹងនិងឲ្យមានផលានិសង្សច្រើនទៀតផង។ ហេតុនេះទើបលោកអ្នកខ្លះ អាចលះបង់កង្វល់ផ្សេងៗ ទៅសម្ងំចម្រើនសមថកម្មដ្ឋានក្នុងទីស្ងាត់ ដើម្បីឲ្យបានផលានិសង្សនេះផង ដើម្បីឲ្យបានសម្រេចឈានចិត្តដែលជាទីតាំងនៃវិបស្សនាកម្មដ្ឋានផង។ ឯវិបស្សនាភាវនាក៏ជាករណីយកិច្ចត្រូវធ្វើបន្ទាប់មកពីការចម្រើនចតុរារក្ខកម្មដ្ឋាន ដែលហៅថាសមថភាវនានោះដែរ។ ហេតុនោះ កាលបានភាវនារំឭកគុណព្រះរតនត្រ័យ ផ្សាយមេត្តា ចម្រើនអសុភៈនិងរំឭកសេចក្តីស្លាប់រួចហើយ តែងភាវនាវិបស្សនាកម្មដ្ឋាន ពិចារណាអត្តភាពទាំងមូលឲ្យឃើញថាគ្រាន់តែជានាមរូបឬគ្រាន់តែជាខន្ធ៥ជាដើមប៉ុណ្ណោះ មិនមែនជាសត្វបុគ្គលគេឯងទេ ហើយលើកសភាវធម៌ទាំងនេះឡើងកាន់ត្រៃលក្ខណ៍ភាវនាបញ្ជាក់ឲ្យឃើញថាមិនទៀង ព្រោះកើតហើយរលត់ទៅនិងប្រែក្លាយទៅជាសភាពផ្សេងៗ, ជាទុក្ខព្រោះក្តៅដោយភ្លើងកិលេសនិងភ្លើងទុក្ខគ្រប់រយៈ

កើតរលត់និងប្រែក្លាយ, ជាអនត្តាមិនមែនខ្លួន ព្រោះមិននៅក្នុងអំណាច ដើម្បីរំលាយនូវឧបាទានសេចក្តីប្រកាន់តាមលោកសម្មតិថា ជារបស់យើង ថាជាយើង នឹងថាជាខ្លួនប្រាណរបស់យើង ដែលជាហេតុឆេះក្តៅ ឲ្យអស់សូន្យទៅពីខន្ធសន្តានហើយ បាននូវព្រះនិព្វានគ្មានឆេះដោយភ្លើងទុក្ខនិងភ្លើងកិលេសឡើយ។ សមនឹងពុទ្ធភាសិតថាៈ

សីលេន វិតិក្កមន្តំ បរិយុដ្ឋំ សមាធិនា

បញ្ញាយ អនុសយំ ជិន្នំ បត្តោ និព្វានមុត្តមំ។

(អ្នកប្រាជ្ញ) តែងលះកិលេស (រាគៈ ទោសៈ មោហៈ) ថ្នាក់វិតិក្កមៈ ដោយសីល, ថ្នាក់បរិយុដ្ឋាន ដោយសមាធិ, ថ្នាក់អនុស័យ ដោយបញ្ញា ទើបបានសម្រេចព្រះនិព្វានដ៏ខ្ពង់ខ្ពស់។

ជនជាតិខ្មែរ ទាំងបព្វជិតទាំងគ្រហស្ថ ច្រើនតែបានភាវនាអប់រំចិត្តដោយសមថៈនិងវិបស្សនា តាំងពីបុរាណកាល ដូចពណ៌នាមកនេះ។

ដូច្នេះហៅថា វប្បធម៌ពុទ្ធសាសនាខាងការប្រតិបត្តិ។

ស្រាវជ្រាវដោយៈ ជាច់ សុគឹម